# ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ ជួបប្រតិភូអង្គការ **UNIDO**



នៅព្រឹកថ្ងៃទី០៧ ខែ ធ្នូ ឆ្នាំ២០១៥ ឯកឧត្តម ចម ប្រសិទ្ធ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានទទួលជួបប្រតិភូអង្គការអភិវឌ្ឍន៍ឧស្សាហកម្មនៃអង្គការសហប្រជាជាតិ ហៅកាត់ថា UNIDO ដឹកនាំ



ដោយលោក **Edward Clarence-Smith** នាយកប្រចាំតំបន់នៃអង្គការ UNIDO ដែលមានមូលដ្ឋាននៅប្រទេសថៃ ដើម្បីពិភាក្សាការងារនៅទីស្ដីការក្រសួង ។

គោលបំណងនៃជំនួបពិភាក្សា គឺដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងពិនិត្យមើលនូវវឌ្ឍនភាពការងារ ក៏ដូចជាពិនិត្យមើលលទ្ធភាពថ្មីៗ សម្រាប់អង្គការ UNIDO ជួយដល់ក្រសួងឧស្សាហកម្ម និងងសិប្បកម្ម លើវិស័យចាំបាច់ និងអាទិភាពមួយចំនួន។

លោកនាយក **Edward Clarence-Smith** បានបង្ហាញនូវការចាប់អារម្មណ៍ពីគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ពីឆ្នាំ២០១៥-២០២៥ ដែលជាឧបករណ៍តម្រង់ទិសដ៏មានសារៈសំខាន់ ដើម្បីកម្ពុជាឈានទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចិរភាព របស់អង្គការសហប្រជាជាតិ ។ ក្នុងនោះសហគមន៍សេដ្ឋកិច្ចអាស៊ានក៏ជាបរិបទថ្មីមួយសម្រាប់កម្ពុជាពង្រឹងវិស័យឧស្សាហកម្មរបស់ខ្លួនផងដែរ ។

មានប្រសាសន៍នាឱកាសនោះ ឯកឧត្តម ទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ បានសម្តែងការស្វាគមន៍ និងថ្លែងអំណរគុណដល់អង្គការ UNIDO ដែលបានសហការជួយជាជំនួយបច្ចេកទេស និងថវិកា ក៏ដូចជាការផ្ទេរបច្ចេកវិទ្យាជាច្រើនដល់ស្ថាប័នពាក់ព័ន្ធកម្ពុជា ។ ក្នុងនោះ ក៏មានក្រសួងឧស្សាហកម្ម និងសិប្បកម្មផងដែរ ។

ឯកឧត្តម ទេសរដ្ឋមន្ត្រី បានស្នើឱ្យតំណាងអង្គការ UNIDO ពិចារណាសហការជួយដល់កម្ពុជា ក៏ដូចជាក្រសួងនូវចំណុចចាំបាច់មួយចំនួនមានដូចជាៈ-ការចងក្រងជាកម្រងឧស្សាហកម្ម ផ្តោតទៅលើវិស័យមួយចំនួន ដូចជា ឧស្សាហកម្មរថយន្ត និងកៅស៊ូជាដើម-ការអភិវឌ្ឍន៍វិស័យសហគ្រាសខ្នាតតូច និងមធ្យម និងសិប្បកម្ម-ជួយបញ្ជូនអ្នកបច្ចេកទេសដើម្បីពិនិត្យវាយតម្លៃដល់មន្ទីរពិសោធន៍ដែលមាននៅក្នុងក្រសួង ងាយស្រួលដឹងពីកង្វះខាតនិងតម្រូវការឧបករណ៍ចាំបាច់ថ្មីៗថែមទៀត-ជួយបណ្តុះបណ្តាលដល់មន្ត្រីមន្ទីរពិសោធន៍កម្ពុជា-ជួយរៀបចំគំរូប្លង់មន្ទីរពិសោធន៍ និងបំពាក់ឧបករណ៍ពិសោធន៍ថ្មីៗបន្ថែមទៀត-ជំនួយបច្ចេកទេសទាក់ទងវិស័យឧស្សាហកម្មកាន់តែបៃតង (Cleaner Production) និងជួយរៀបចំបទដ្ឋានគតិយុទ្ធ និងនីតិវិធី នៃការគ្រប់គ្រង ការនាំចូល ការចែកចាយ ការប្រើប្រាស់ រឺការស្តុកទុកសារធាតុគីមី និងផលិតផលដែលមានសារធាតុគីមីជាដើម ។

ជាការឆ្លើយតប លោក **Edward Clarence-Smith** នាយកប្រចាំតំបន់នៃអង្គការ UNIDO បានចាត់ទុកសំណើរខាងលើ មានលក្ខណៈសមស្រប និងចាំបាច់ ហើយអង្គការ UNIDO និងយកបញ្ហាទាំងអស់នេះ ដាក់ចូលក្នុងគម្រោងផែនការរបស់ខ្លួន ដើម្បីពិនិត្យលទ្ធភាពជួយដល់កម្ពុជា តាមដំណាក់កាលនីមួយៗ ។

